ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
..............

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៦៨០/២០.៧.២០១៥
សាលដីកា
លេខ: ១០ ក្រVស/១៤.៣.២០១៦

# គាននាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជា សាធារណៈ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ ដោយមានសមាសភាពដូចតទៅ:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធាន
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជី</u>**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៦៨០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ រវាង៖

១- ជនជាប់ចោទឈ្មោះ [redacted] ស៊ុល ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិឥស្លាម មុខរបររកស៊ីទិញគោ ទីកន្លែងកំណើតភូមិថ្មគោល ឃុំកោប្រាំ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃ [redacted] ស្រុកស្នួល ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន។ ចាប់ខ្លួនថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៤, ឃុំខ្លួនថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ។

២- ជនជាប់ចោទឈ្មោះ [redacted] លីទី ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរបើកឡាន ទីកន្លែងកំណើតភូមិព្រែកតាចឹង ឃុំបុសលាវ ស្រុកចិត្របុរី ខេត្តក្រចេះ ទីលំនៅសព្វថ្ងៃ [redacted] ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធ ឈ្មោះ [redacted] ទោសពី មុនគ្មាន ចាប់ខ្លួនថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤, ឃុំខ្លួនថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ។

មេធាវីការពារជនជាប់ចោទ លោក [redacted] ម៉ាច ។

៣- ជនជាប់ចោទឈ្មោះ [redacted] ទ្រី ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតនិងទីលំនៅសព្វថ្ងៃ [redacted] ស្រុកស្នួល ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤,



Scanned by CamScanner

ឃុំខ្លួនថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ។

មេធាវីការពារជនជាប់ចោទ លោក [redacted]ភី ។

ជាប់ចោទពីបទៈ រក្សាទុក ដឹកជញ្ជូន ឬជួញដូរ, ចាត់ចែងឲ្យប្រើប្រាស់, សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិក្បាលស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០, មាត្រា ៤២, មាត្រា ៤៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ៦ដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ វេលាម៉ោង ១៥ និង ៣០នាទី លោក [redacted]ព្រះរាជអាជ្ញា និងលោក [redacted] ព្រះរាជអាជ្ញារង បានដឹកនាំកម្លាំងអធិការដ្ឋាននគរបាលស្រុកស្នួល សហការជាមួយកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលស្នួល បានចុះបង្ក្រាបការជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចផ្ទះរបស់ឈ្មោះ [redacted]ទ្រី ស្ថិតនៅ ភូមិក្បាលស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ។ នៅក្នុងការប្រតិបត្តិការនោះ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនឈ្មោះ[redacted]ស៊ុល ឈ្មោះ [redacted]ល័មី ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ហ៊ុយសេន ព្រមទាំងដកហូតម៉ូតូពីឈ្មោះ [redacted] ហ៊ុយសេន ចំនួនមួយគ្រឿង ហើយក្នុងកែបម៉ូតូនោះដកហូតបានថ្នាំញៀន(ម៉ាទឹកកក) ចំនួនបីកញ្ចប់(ពីរកញ្ចប់តូច និងមួយកញ្ចប់ធំ) និងរកឃើញចំនួនបួនកញ្ចប់តូចទៀត ដែលឈ្មោះ[redacted]ហ៊ុយសេន ព្យាយាមបោះចោលនៅក្រោមផ្ទះ, ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួនមួយ, កន្ត្រៃចំនួនមួយ, អត្តសញ្ញាណប័ណ្ណចំនួនមួយ និងថង់ផ្លាស្ទិកសម្រាប់វេចគ្រឿងញៀនមួយចំនួន ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០៨ (ក) ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តក្រចេះ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ផ្តន្ទាទោសៈ

- ឈ្មោះ[redacted] ហ៊ុយសេន ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរឥស្លាម
- ឈ្មោះ [redacted] ស៊ុល ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរឥស្លាម
- ឈ្មោះ[redacted]ល័មី ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ
- ឈ្មោះ [redacted]ទ្រី ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ
- ឈ្មោះ [redacted] ម៉ាប់ ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ ក្នុងម្នាក់ៗ ចំនួន ០៣ឆ្នាំ(បីឆ្នាំ) តែទោសនេះត្រូវអនុវត្តទោសពន្ធនាគារកំណត់ ក្នុងម្នាក់ៗ ចំនួន ០២ឆ្នាំ ទោសសល់ពីនេះត្រូវព្យួរ ពីបទៈ រក្សាទុក ដឹកជញ្ជូន ឬជួញដូរ,ចាត់ចែងឲ្យប្រើប្រាស់, សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិក្បាលស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០, ៤២, ៤៤, ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ នៃព្រះរាជាណាចក្រ កម្ពុជា និងមាត្រា ១០៦, ១០៧ និង ១០៨ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។



Scanned by CamScanner

២- វត្ថុចាប់យកមាន៖ សារធាតុញៀនឈ្មោះមេតំហ្វេតាមីន ([illegible]) សរុបចំនួន ០៩កញ្ចប់ និងថង់សម្រាប់ច្រកគ្រឿងញៀនមួយចំនួន- កន្ត្រៃចំនួន០១- ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន ០១- ស្ករក្រាមពណ៌សចំនួន ៦,៨៥គីឡូក្រាម ត្រូវបំបែកបំផ្លាញចោល រីឯរថយន្តសញ្ញាពពរប័ណ្ណសញ្ញាពីខ្មែរ ចំនួន០១ ត្រូវបំបែករូបប្រគល់ឲ្យម្ចាស់វិញ ចាប់ពីសាលក្រមនេះ ចូលជាស្ថាពរតទៅ ។

៣- សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៥ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]ហ៊ុយសេន-ហៅ ស៊ិល-តែ លីទី-សុខ ទ្រី កំបាំងមុខជនជាប់ចោទឈ្មោះ[redacted]ម៉ាប់ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ១៦ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] ទ្រី ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០៨ (ក) ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តក្រចេះ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] លីទី ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០៨ (ក) ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តក្រចេះ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ២០ ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] ស៊ិល ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០៨ (ក) ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តក្រចេះ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ចៅក្រមសាលាឧទ្ធរណ៍ ។

-បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ របស់តំណាងមហាអយ្យការអម សាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ ក្រឡាបញ្ជី អានចម្លើយជនជាប់ចោទឈ្មោះ [redacted]ទ្រី [redacted]លីទី,[redacted] ស៊ិល បានឆ្លើយនៅសាលាដំបូងខេត្តក្រចេះ ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

អង្គហេតុពាក់ព័ន្ធនឹងជនជាប់ចោទ ដែលត្រូវបានអយ្យការសាលាដំបូងចោទប្រកាន់ពីបទ រក្សាទុក ដឹកជញ្ជូន ឬជួញដូរ, ចាត់ចែងឲ្យប្រើប្រាស់, សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០, ៤២, ៤៤, ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តំណាងមហាអយ្យការមិនយល់ទាស់អង្គហេតុនេះទេ, ឃើញថា សេចក្តីសម្រេចរបស់សាលាដំបូងមានលក្ខណៈសមរម្យ សុំក្រុមប្រឹក្សាពិចារណា និងសម្រេចតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

លោក [redacted]រ៉ាវី មេធាវីការពារជនជាប់ចោទ [redacted]ទ្រី សន្និដ្ឋានថា: សាលាដំបូងខេត្តក្រចេះ បាន



Scanned by CamScanner

សម្រេចផ្តន្ទាទោសកូនក្តីខ្លួន [redacted] ទ្រី ពីបទ សម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលអង្គហេតុនេះជាអង្គហេតុពុំច្បាស់ ហើយក៏មិនមានអង្គហេតុដែលបញ្ជាក់ថា ប្រើប្រាស់នោះទេ គ្រឿងញៀននេះមិនមានភស្តុតាងណាបញ្ជាក់ថា ប្រើប្រាស់នោះទេ ក្នុងប្រតិបត្តិការនេះ មានតែអង្គហេតុពុំច្បាស់ ដូចនេះសំណូមពរលោកប្រធាន លើចំណុចផ្តន្ទាទោសរបស់តុលាការខេត្តក្រចេះ ដែលផ្តន្ទាទោសកូនក្តីខ្លួន ពីបទ សម្រួលឲ្យប្រើប្រាស់ និងសុំលើកលែងចោទ និងសុំឲ្យមានការដោះលែងកូនក្តីខ្លួនដោយអនុគ្រោះ ។

លោក [redacted] ម៉ាច មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ទ្រី និងឈ្មោះ[redacted] ស៊ុល សន្និដ្ឋានថា: កូនក្តីខ្លួនទាំងពីនាក់ នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] ស៊ុល បានទៅផ្ទះ [redacted]ទ្រី ហើយឈ្មោះ[redacted]ទី ជាអ្នកបើកឡាន ពេលទៅដល់ផ្ទះឈ្មោះ [redacted]ទ្រី ស្រាប់តែប៉ូលីសឃាត់ខ្លួនតែម្តង, តាមចម្លើយរបស់[redacted]ទី ថា ពេលទៅដល់ក៏ត្រូវចាប់ខ្លួន។ សុំក្រុមប្រឹក្សាសម្រេចកេយុត្តិធម៌ដល់កូនក្តីខ្លួន ។

ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍

## យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ របស់ជនជាប់ចោទ ឈ្មោះ [redacted] ទ្រី, បណ្តឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted] លីទី និងបណ្តឹងឧទ្ធរណ៍លេខ ២០ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៥ របស់ឈ្មោះ[redacted] ស៊ុល ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- តាមចម្លើយនៅថ្នាក់ក្រោមជនជាប់ចោទ:

-ឈ្មោះ [redacted] ទ្រី ថា ខ្លួនពុំដែលលក់ដូរ ឬប្រើប្រាស់គ្រឿងញៀនទេ។ ខ្លួនស្គាល់ឈ្មោះ[redacted], លីទី និង ហ៊ុយសេន ព្រោះនៅផ្ទះជិតគ្នា, ចំពោះគ្រឿងញៀនដែលនៅរាយប៉ាយក្រោមផ្ទះខ្លួន, ខ្លួនមិនដឹងទេ ។

-ឈ្មោះ [redacted] ស៊ុល ថា នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ នោះ ខ្លួនបានទៅផ្ទះ[redacted]ទ្រី ដើម្បីពិភាក្សាពីការទិញឈើធ្វើគុប្រើប្រាស់។ ខ្លួនពុំដឹងថា អ្នកណាបោះចោលគ្រឿងញៀននៅក្រោមផ្ទះ [redacted]ទ្រី ទេ។ ខ្លួនពុំដែលលក់ដូរគ្រឿងញៀនទេ តែធ្លាប់ប្រើគ្រឿងញៀនប្រាកដមែន ។

-ឈ្មោះ [redacted] លីទី ថា នៅថ្ងៃកើតហេតុ ខ្លួននៅនឹងផ្ទះ [redacted]ទ្រី, ខ្លួនជាអ្នកបើកឡាន ដឹងឥវ៉ាន់ឲ្យឈ្មោះ [redacted] ទ្រី, ខ្លួនមិនជាប់ពាក់ពន្ធ័នឹងគ្រឿងញៀនទេ តែរយៈកន្លងទៅខ្លួនធ្លាប់ ប្រើប្រាស់គ្រឿងញៀនមែន ។



Scanned by CamScanner

៣- មានភស្តុតាង បញ្ជាក់ពីទោសកំហុសជនជាប់ចោទឈ្មោះ [redacted], [redacted] និង [redacted] ពីបទៈ ការទុក, ដឹកជញ្ជូន, ជួញដូរ, ចាត់ចែងឲ្យប្រើប្រាស់, សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិក្បាលស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា៤០ មាត្រា៤២ មាត្រា៤៤ និងមាត្រា៤៨ នៃច្បាប់ស្តីពីការប្រើប្រាស់ត្រួតពិនិត្យគ្រឿងញៀន ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ០៨-ក- ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តក្រចេះ សម្រេចមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងច្បាប់, គួរតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted], បណ្តឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] និងបណ្តឹងឧទ្ធរណ៍លេខ ២០ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៨ -ក- ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តក្រចេះ ទុកជាបានការពេញទាំងមូល ។

៣- បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទទាំង០៣នាក់ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ ប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ចំពោះមុខមេធាវីការពារសិទ្ធិជនជាប់ចោទ, កំបាំងមុខជនជាប់ចោទទាំង០៣នាក់, បើកផ្លូវតវ៉ាតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខាៈ [redacted] | ហត្ថលេខាៈ [redacted] | ហត្ថលេខាៈ [redacted] |

................................................................................................

| | |
|---|---|
| បានឃើញ | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
| ប្រធានក្រុមប្រឹក្សាជំនុំជម្រះ | ភ្នំពេញ, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ |
| | ក្រឡាបញ្ជី |
| [redacted] | [redacted] |

Scanned by CamScanner